**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែកុម្ភៈ ឆ្នាំ២០១៨

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ :

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានៈ

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០១លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីសម្ពោធអគារមន្ទីរពេទ្យ **សម្តេចឪ-សម្តេចម៉ែ** ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់របស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅក្នុងបរិវេណមន្ទីរពេទ្យបង្អែកខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

-អញ្ជើញជូនព្រះរាជដំណើរ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ព្រះអង្គស្តេចយាងចេញពីមាតុប្រទេសទៅកាន់សាធារណរដ្ឋប្រជាមានិតចិន

-អនុញ្ញាតជូនឯកឧត្តម NGUYEN THIEN NHAN សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម លេខាគណៈកម្មាធិការបក្សទីក្រុងហូជីមិញ និងជាប្រធានក្រុមតំណាងរដ្ឋសភាទីក្រុងហូជីមិញ និងគណៈប្រតិភូចូលជួបសម្តែងការគួរសម

-អនុញ្ញាតជូនលោកជំទាវ Manika Jain ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋឥណ្ឌា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម

-អនុញ្ញាតជូនឯកឧត្តម Vu Quang Minh ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព

នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្តែងការគួរសម

-អនុញ្ញាតឲ្យថ្នាក់ដឹកនាំសមាគមនិស្សិតកម្ពុជាប្រចាំនៅសាធារណរដ្ឋប្រជាមានិតចិន ចំនួន២៣រូប ចូលជួបសម្តែងការគួរសម

-អញ្ជើញជាអធិបតីបើកកម្មវិធីប្រកួតវាយកូនហ្គោលពានរង្វាន់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** នៅទីលានវាយកូនហ្គោលដឺប្រេ្កនភ្នំពេញ រាជធានីភ្នំពេញ

-អញ្ជើញនាំយកបច្ច័យ ទេយ្យវត្ថុ អង្ករ គ្រឿងឧបភោគ បរិភោគ និងចង្ហាន់ទៅវេរប្រគេន**សម្តេចព្រះវនរ័តកិត្តិបណ្ឌិត ណយ ច្រឹក** ព្រះសង្ឃនាយករងទី៣ នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះគ្រូចៅអធិការវត្ត ព្រមទាំងព្រះសង្ឃ ព្រះសមណសិស្ស និស្សិត សរុបចំនួន៩១អង្គ គង់នៅវត្តច័ន្ទបុរីវង្ស ក្នុងសង្កាត់សំរោង ខណ្ឌព្រែកព្នៅ

-អញ្ជើញចូលរួមរំលែកទុក្ខ និងពិធីបញ្ចុះសពលោកជំទាវ **ហ៊ុន វណ្ណាវឌ្ឍនា** នៅភូមិព្រែកស្នង ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល

-អញ្ជើញចូលរួមរំលែកទុក្ខគ្រួសារសព ឯកឧត្តម **ឯក វីរៈដេដ្ឋ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅវត្តកៀនស្វាយក្នុង សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៧ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣០ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ ព្រឹទ្ធសភា ឫាន** :

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញជាអធិបតីក្នុងពិធីជួបសំណេះសំណាលជាមួយសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ មកពីស្រុកអង្គរជ័យចំនួន៨២នាក់ ស្រុកបន្ទាយមាសចំនួន៧២នាក់ ស្រុកឈូកចំនួន៩៨នាក់ ស្រុកជុំគិរីចំនួន៤១នាក់ ស្រុកដងទង់ចំនួន៥៣នាក់ ស្រុកកំពង់ត្រាចចំនួន៨៣នាក់ ស្រុកទឹកឈូចំនួន៩២នាក់ ក្រុងកំពតចំនួន៣៣នាក់ ក្រុងកែបចំនួន៣១នាក់ និងថ្នាក់ដឹកនាំខេត្តកំពត និងខេត្តកែប ដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ ជាសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ទីប្រឹក្សា មន្ត្រីខុទ្ទកាល័យ ព្រមទាំងអាជ្ញាធរខេត្តកំពត គ្រប់លំដាប់ថ្នាក់សរុបចំនួន៧៣១នាក់

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការរោងចក្រផលិតស៊ីម៉ង់ត៍របស់ក្រុមហ៊ុន **ជីប ម៉ុង អ៊ិនស៊ី ស៊ីមេន ខបភើរេសិន** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**នាយករដ្ឋមន្ត្រីនៃព្រះរាជា-

ណាចក្រកម្ពុជា នៅភូមិព្រៃតាព្រិត ឃុំស្តេចគង់លិច ស្រុកបន្ទាយមាស ខេត្តកំពត

-អញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរ និងប្រជាពលរដ្ឋ នៅខេត្តកំពត

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៨ច្បាប់ និង ជ្រាបជាព័ត៌មានចំនួន៣៣ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា ប្បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក និងប្រជុំ ពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមប្រជុំពិនិត្យរបាយការណ៍លទ្ធផលការងារប្រចាំឆ្នាំ២០១៧ និង ទិសដៅការងារឆ្នាំ២០១៨ របស់សមាគមមិត្តភាពកម្ពុជា-ចិន

-អញ្ជើញជាអធិបតី និងដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ចុះជួប សំណេះសំណាល និងសួរសុខទុក្ខជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន៩៥៨នាក់ នៅ ទូទាំង១១ស្រុក-ក្រុងក្នុងខេត្តកណ្តាល

-អញ្ជើញពិនិត្យមើលការជួសជុលសាលប្រជុំពេញអង្គព្រឹទ្ធសភា

-អញ្ជើញចុះពិនិត្យមើលការសាងសង់ព្រះវិហារ និងប្រគេនបច្ច័យចំនួន៤,០០០$ សម្រាប់ក្រាលឥដ្ឋការ៉ូឡា ជុំវិញព្រះវិហារ នៅវត្តប្រាំបីមុំ ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ

-អញ្ជើញចូលរួមបុណ្យ៧ថ្ងៃសព លោកជំទាវ **ហ៊ុន វណ្ណវឌ្ឍនា** នៅភូមិគ្រឹះលេខ ១១៣៤ ផ្លូវលេខ១១០ ក្រុងតាខ្មៅ ខេត្តកណ្តាល

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសព អ្នកឧកញ៉ា **ដួង ឈីវ** នៅគេហដ្ឋានផ្ទះ លេខ២០៧-២០៩ ផ្លូវលេខ១៩ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៧៧ច្បាប់ និង ជ្រាបជាព័ត៌មានចំនួន៥៣ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០៣លើក:**

១.ពិនិត្យ និងសម្រេចលើរបាយការណ៍អនុវត្តចំណូល-ចំណាយថវិកាព្រឹទ្ធសភា ឆ្នាំ២០១៧

២.ពិនិត្យ និងសម្រេចអំពីគោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភា ឆ្នាំ២០១៨

៣.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៦ ព្រឹទ្ធសភា សុំដាក់៖

-សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មក្រមព្រហ្មទណ្ឌ

-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

៤.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៩ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម

៥.កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តសម័យប្រជុំលើកទី១១ព្រឹទ្ធសភា នីតិកាលទី៣ ។

**៣. សម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក** :

១.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

២.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មក្រមព្រហ្មទណ្ឌ

៣.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

៤.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម ។

**៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែកុម្ភៈនេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោមៈ

**៤.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៣ ច្បាប់ ។

### ៤.២. មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន និងជួបក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តព្រះសីហនុ និងខេត្តកោះកុង ។

### ៤.៣. មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន០៥ករណី បញ្ជូនពាក្យបណ្តឹងទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៥ករណី ធ្វើការឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៥ករណី ព្រមទាំងបានទទួលពាក្យបណ្តឹងជូនជ្រាបចំនួន១៣ករណី និងជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន០១ករណី

-អញ្ជើញចូលរួមធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភាជូនសាស្ត្រាចារ្យ និងនិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងវិទ្យាស្ថានជាតិសង្គមកិច្ច

-អញ្ជើញចូលរួមប្រជុំរាយការណ៍អំពីលទ្ធផល នៃការចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី២៦ របស់វេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិច (APPF) នៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងពិភាក្សាត្រៀមរៀបចំកិច្ចប្រជុំប្រចាំឆ្នាំលើកទី២៧ របស់វេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិច (APPF) ដែលនឹងប្រារព្ធធ្វើនៅព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមទស្សនាការបង្ហាញសិល្បៈរួមគ្នាដើម្បីអបអរសាទរក្នុងឱកាសគម្រប់ខួបលើកទី៦០ឆ្នាំ នៃការបង្កើតចំណងការទូតរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយសាធារណរដ្ឋប្រជាមានិតចិន

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត ក្រុង រាជធានីភ្នំពេញ ចំនួន២៣១លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាននិងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៤៩លើក ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **ម៉ុង ឫទ្ធី** ទទួលជួបពិភាក្សាការងារជាមួយលោក Michael Tan Keng Siong ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ដើម្បីរកឱកាសវិនិយោគ នៅព្រះរាជាណាចក្រកម្ពុជា លើវិស័យកសិកម្ម កសិឧស្សាហកម្មកែច្នៃ និងលំនៅដ្ឋាន ក្នុងនាមជាតំណាងប្រទេសសិង្ហបុរី

-ឯកឧត្តម **ប៊ូ ថង** អញ្ជើញជួបសំណេះសំណាលការងារជាមួយឯកឧត្តមឯកអគ្គ-រដ្ឋទូតឡាវប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងអនុញ្ញាតឲ្យឯកឧត្តម **វីរ៉ាវង់ វាឡាវង់** អគ្គកុងស៊ុលឡាវប្រចាំនៅខេត្តស្ទឹងត្រែង ចូលជួបសម្តែងការគួរសម និងសំណេះសំណាលការងារ នៅក្រុងបានលុង ខេត្តរតនគិរី ។

ថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណ:រដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសា